ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការផ្សព្វផ្សាយព័ត៌មានមិនពិតជុំវិញការបើកប្រាក់ឈ្នួលដល់បងប្អូនកម្មករនិយោជិត នៃក្រុមហ៊ុន វ៉ាយ & ដាប់បែលយូ ហ្គាមេន (Y & W GARMENT CO., LTD.)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់បងប្អូនកម្មករនិយោជិតនៃក្រុមហ៊ុន វ៉ាយ & ដាប់បែលយូ ហ្គាមេន (Y & W GARMENT CO., LTD.) ជ្រាបថា នារសៀលថ្ងៃទី១៩ ខែមីនា នេះ មានការបំផុសព័ត៌មានមិនពិតថា នៅព្រឹកស្អែក ថ្ងៃទី២០ ខែមីនា ក្រសួងនឹងធ្វើការបើកប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗជូនបងប្អូនកម្មករនិយោជិត។ ក្រសួងសូមបញ្ជាក់ថា នេះជាព័ត៌មានមិនពិត និងសូមបងប្អូនកម្មករនិយោជិតកុំជឿលើការផ្សព្វផ្សាយ និងបំផុសព័ត៌មានមិនពិតនេះឱ្យសោះ។

បច្ចុប្បន្ននេះ ក្រសួងបានទទួលរួចហើយនូវដីការក្សាការពារ ហើយសាលាដំបូងរាជធានីភ្នំពេញក៏កំពុងបំពេញនីតិវិធីលក់ឡៃឡុងទ្រព្យសម្បត្តិ ដើម្បីបានថវិកាទូទាត់ជូនបងប្អូនកម្មករនិយោជិត។ ក្រោយពេលដែលតុលាការបានបញ្ចប់នីតិវិធី និងលក់ឡៃឡុងទ្រព្យសម្បត្តិក្រុមហ៊ុនបានថវិការួចរាល់ហើយនោះ ក្រសួងនឹងប្រកាសជាសាធារណៈឱ្យបងប្អូនកម្មករនិយោជិតជ្រាប និងមកបើកប្រាក់ឈ្នួលនិងប្រាក់បំណាច់ផ្សេងៗជាក់ជាពុំខាន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមអំពាវនាវដល់បុគ្គលទាំងឡាយ ដែលមានបំណងចង់ជួយដល់បងប្អូនកម្មករនិយោជិតពិតប្រាកដ សូមសិក្សាស្វែងយល់អំពីច្បាប់ និងនីតិវិធីនៃការលក់ឡៃឡុង ឱ្យបានត្រឹមត្រូវ មុននឹងផ្សព្វផ្សាយព័ត៌មានដល់បងប្អូនកម្មករនិយោជិត ចៀសវាងបង្កឱ្យមានការយល់ខុស។

សូមបងប្អូនកម្មករនិយោជិតដែលមានការងារថ្មី មេត្តាបន្តធ្វើការជាធម្មតារហូតដល់មានការជូនដំណឹងជាផ្លូវការពីក្រសួងក្នុងពេលឆាប់ៗខាងមុខនេះ។ ដោយឡែក សម្រាប់បងប្អូនកម្មករនិយោជិត ដែលមិនទាន់មានការងារធ្វើ សូមមកទទួលឱកាសការងារថ្មីពីទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ដែលប្រចាំការនៅមុខរោងចក្រ និងក្នុងតំបន់ ដែលបងប្អូនស្នាក់នៅ។ សូមបងប្អូនមេត្តាកុំរង់ចាំតែប្រាក់ខែចាស់ ហើយទុកឱកាសការងារថ្មី និងប្រាក់ខែថ្មីឱ្យរំលងហួស។ អ្វីដែលជាអត្ថប្រយោជន៍នៅរោងចក្រចាស់នឹងមិនបាត់បង់ឡើយ នៅពេលដែលនីតិវិធីតុលាការ និងការលក់ឡៃឡុងត្រូវបានបញ្ចប់នៅពេលខាងមុខ។

អាស្រ័យហេតុនេះ សូមបងប្អូនកម្មករនិយោជិត មេត្តាជ្រាបជាព័ត៌មាន និងបន្តរក្សាភាពស្ងប់ស្ងាត់។

ថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩